**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អង្គការមូលនិធិអេ២១

លេខ ១៨០/.២៣

# គោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**កម្មវត្ថុ៖** សំណើសុំការអនុញ្ញាត និងគោរពអញ្ជើញ លោកជំទាវ ចូលរួមជាអធិបតីក្នុងព្រឹត្តិការណ៍បញ្ឈប់អំពើជួញដូរមនុស្ស។

**យោង៖** អនុស្សរណៈនៃការយោគយល់គ្នារវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការមូលនិធិអេ២១ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០។

តបតាមកម្មវត្ថុ និងយោងខាងលើនាងខ្ញុំសូមគោរពជូន **លោកជំទាវ** មេត្តាជ្រាបថា៖ អង្គការមូលនិធិអេ២១កម្ពុជា នឹងរៀបចំព្រឹត្តិការណ៍ផ្សព្វផ្សាយមួយក្រោមប្រធានបទ "បញ្ឈប់អំពើជួញដូរមនុស្ស" ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងពង្រឹងសមត្ថភាពដល់សាធារណៈជនអំពីអំពើជួញដូរមនុស្ស នៅក្នុងក្រុងសៀមរាប ខេត្តសៀមរាប តាមរយៈកិច្ចសហការជាមួយរដ្ឋបាលខេត្តសៀមរាប និងគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តសៀមរាប។ ព្រឹត្តិការណ៍នេះ នឹងរៀបចំនៅថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ដែលមានអ្នកចូលរួមសរុបចំនួន ៥០០នាក់។ ដើម្បីញ៉ាំងឲ្យព្រឹត្តិការណ៍នេះប្រព្រឹត្តទៅបានប្រកបដោយភាពអធិកអធម អង្គការមូលនិធិអេ២១កម្ពុជា ស្នើសុំការអនុញ្ញាត និងសូមគោរពអញ្ជើញ លោកជំទាវ ផ្តល់កិត្តិយសចូលរួមជាអធិបតីក្នុងព្រឹត្តិការណ៍នេះ។

អាស្រ័យដូចបានគោរពជូន និងស្នើសុំខាងលើ សូម **លោកជំទាវ** មេត្តាពិនិត្យ និងអញ្ជើញចូលរួមដោយអនុគ្រោះ។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ថ្ងៃអង្គារ ០៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

**នាយិកាប្រចាំប្រទេស**

Krista Schaaf

**កញ្ញា គ្រីស្ទីន ស្កាហ្វ**

មូលនិធិអេ២១
A21 FOUNDATION

# ព្រាងលម្អិតអំពីព្រឹត្តិការណ៍

ព័ត៌មានលម្អិតអំពីព្រឹត្តិការណ៍ និងផែនការព្រាងសកម្មភាពដែលនឹងគ្រោងអនុវត្តៈ

១. ព្រឹត្តិការណ៍ដើរដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស

-គោលដៅរួម ៖ ផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងនិងពង្រឹងសមត្ថភាពដល់សាធារណៈជនស្តីពីអំពើជួញដូរមនុស្ស ។

-ទីតាំងស្នើសុំរៀបចំព្រឹត្តិការណ៍៖ ទីធ្លាសួនច្បារព្រះរាជដំណាក់ ក្រុងសៀមរាប

-កាលបរិច្ឆេទ ៖ ថ្ងៃពុធ ទី ១១ ខែ តុលា ឆ្នាំ ២០២៣

-ពេលវេលា ៖ រយៈពេល ៣ម៉ោង ចាប់ពីម៉ោង ៧ រហូតដល់ ១០ ព្រឹក

-ចំនួនអ្នកចូលរួម ៖ ៥០០ នាក់

-រយៈចម្ងាយនៃការដើរផ្សព្វផ្សាយ ៖ ២.១ គីឡូម៉ែត្រ

-ទីតាំងនៃការដើរផ្សព្វផ្សាយ ៖ ក្រុងសៀមរាប (ដូចបង្ហាញក្នុងផែនទីដែលបានភ្ជាប់ជូនខាងក្រោម)

-អ្នករៀបចំព្រឹត្តិការណ៍ ៖ អង្គការមូលនិធិអេ២១កម្ពុជា

-វីដេអូគម្រូបង្ហាញក្បួនដើរ ៖ https://www.a21.org/content/walk-for-freedom-2022/gtaf8w

២. ផែនការព្រាងសកម្មភាពផ្សព្វផ្សាយពាក់ព័ន្ធដទៃទៀត (អនុវត្តក្នុងខែតុលា និងខែបន្តបន្ទាប់ក្នុងត្រីមាសទី ៤)

| សកម្មភាព | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|
| ២.១ បន្តរៀបចំការបិទបដាផ្សព្វផ្សាយតាមរយៈរ៉ឺម៉កកង់បី | x | x | x |
| ២.២ ការចងបដាផ្សព្វផ្សាយតាមទីធ្លាសាធារណៈ និង តាមសាលារៀន | X | | |
| ២.៣ ការចែកចាយសម្ភារៈទប់ស្កាត់ជូនដល់ប្រជាពលរដ្ឋ | x | x | X |
| ២.៤ ការបង្ហោះសារផ្សព្វផ្សាយតាមបណ្តាញសង្គម | x | x | X |
| ២.៥ ធ្វើការផ្សព្វផ្សាយស្តីពីសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សតាមរយៈប្រព័ន្ធព័ត៌មានខេត្ត | X | | |
| ២.៦ ចុះផ្សព្វផ្សាយ អប់រំអំពីការជួញដូរមនុស្សដល់សិស្ស និស្សិត | X | | |
| ២.៧ បំពាក់ព័ត៌មានអប់រំ និងសំភារៈស្តីពីអំពើជួញដូរមនុស្សតាមបណ្ណាល័យសាលារៀន | x | x | X |
| ២.៨ បង្កើត ឬ ធ្វើបច្ចុប្បន្នភាពវីដេអូផ្សព្វផ្សាយស្តីពីអំពើជួញដូរមនុស្ស | x | | |
| ២.៩ បង្កើតវីដេអូខ្លីស្តីពីព្រឹត្តិការណ៍បញ្ឈប់អំពើជួញដូរមនុស្ស | X | | |
| ២.១០ បន្តគាំទ្រ គ ជ ប ជ ឬ គ ខ ប ជ រៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ | | | X |

សម្រាប់ព័ត៌មានឬសំណួរបន្ថែមទាក់ទងព្រឹត្តិការណ៍នេះ សូមទាក់ទងមកបុគ្គលិកមូលនិធិអេ២១កម្ពុជា លោក សាញ់ រស្មី អ្នកសម្របសម្រួលគម្រោងទប់ស្កាត់ តាមរយៈទូរស័ព្ទលេខ ០៨៨ ២៣១៣១៣០ ឬអ៊ីម៉ែល raksmey.s@a21.org

ថ្ងៃអង្គារ ៦កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

សៀមរាប ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

**នាយិកាប្រចាំប្រទេស**

Krista Lehorf

**កញ្ញា គ្រីស្ទីន ស្កាហ្វ**

មូលនិធិអេ២១
A21 FOUNDATION

# តារាងព្រាងកម្មវិធី

ព្រឹត្តិការណ៍ដើរដើម្បីបញ្ឈប់អំពើជួញដូរមនុស្ស

ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣

ម៉ោង ៧ ដល់ ១០ ព្រឹក

| ម៉ោង | សកម្មភាព | ទំនួលខុសត្រូវ | ផ្សេងៗ |
|---|---|---|---|
| 7:00 –7:45 | ចុះវត្តមានអ្នកចូលរួម | អេ២១ | |
| 7:45 - 8:00 | ស្វាគមន៍ការអញ្ជើញមកដល់របស់គណៈអធិបតី | អេ២១ | |
| 8:00 - 8:05 | ការគោរពភ្លេងជាតិ | ទាំងអស់គ្នា | |
| 8:05 - 8:10 | មតិស្វាគមន៍ បើកកម្មវិធី និង គោលបំណងនៃព្រឹត្តិការណ៍ | អេ២១ | |
| 8:10 - 8:20 | មតិស្វាគមន៍ និង សារចែករំលែកពី លោកជំទាវ អភិបាលរងនៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ ខ ប ជ | លោកជំទាវ អភិបាលរងខេត្ត | |
| 8:20-8:30 | សារចែករំលែកពី លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស | លោកជំទាវ ជូ ប៊ុនអេង | |
| 8:30-8:40 | គោលការណ៍ណែនាំស្តីពីរបៀបរបបនៃការដើរក្បួន និងវិធានសុវត្ថិភាព | អេ២១ | |
| 8:40-8:50 | ពិធីថតរូបជុំគ្នារវាងអ្នកចូលរួម និង គណៈអធិបតី | ទាំងអស់គ្នា | |
| 8:50-9:00 | ពិធីបង្ហោះប៉ោងប៉ោង ដោយមានភ្ជាប់សារបញ្ឈប់អំពើជួញដូរមនុស្ស | លោកជំទាវ ជូ ប៊ុនអេង | |
| 9:00-9:50 | ចាប់ផ្តើមព្រឹត្តិការណ៍ដើរ ចេញពីគោលដៅ និង ត្រឡប់មកវិញ | អ្នកចូលរួម | |
| 9:50-10:00 | ការថ្លែងអំណរគុណ និង បិទបញ្ចប់កម្មវិធី | អេ២១ | |
| 10:00-10:30 | សម្រាក & ថតរូបអនុស្សាវរីយ៍ | អ្នកចូលរួម | |

*អេ២១កម្ពុជា សុំរក្សាសិទ្ធិក្នុងការកែសម្រួលសេចក្តីព្រាងនៃកម្មវិធីនេះ ឲ្យស្របតាមស្ថានភាពជាក់ស្តែង

*អេ២១កម្ពុជានឹងគោរពយ៉ាងខ្ជាប់ខ្ជួនតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលនិងរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំព្រឹត្តិការណ៍នេះ

*សម្ភារៈ

-អាវយឺត ផ្តល់ជូនដល់មន្ត្រីរាជការនិងសិស្សានុសិស្សដែលចូលរួមដោយឥតគិតថ្លៃ

-សាប៊ូពាក់ពាក់ការពារ ទឹកពិសារបរិសុទ្ធ អាហារសម្រន់ ផ្តល់ជូនអ្នកចូលរួមដោយឥតគិតថ្លៃ

មូលនិធិអេ២១
A21 FOUNDATION

ខ្លឹមសារនៃសារដែលនឹងផ្សព្វផ្សាយក្នុងព្រឹត្តិការណ៍បញ្ឈប់អំពើជួញដូរមនុស្សរួមមាន (ជាភាសាជាតិ និងអង់គ្លេស)៖

<u>ភាសាជាតិ៖</u>

១. រួមគ្នា លុបបំបាត់អំពើជួញដូរមនុស្ស ។

២. អំពើជួញដូរមនុស្សក៏កើតឡើងតាមប្រព័ន្ធអនឡាញផងដែរ!

៣. ក្នុងចំណោមជនរងគ្រោះនៃអំពើជួញដូរមនុស្ស ៤នាក់ មានម្នាក់ជាកុមារ។

៤. បញ្ឈប់អំពើជួញដូរមនុស្ស !

៥. មនុស្សរាប់លាននាក់ជុំវិញពិភពលោកកំពុងរស់ក្នុងទាសភាពនាពេលបច្ចុប្បន្ន។

៦. ៩៩% នៃជនរងគ្រោះកំពុងរង់ចាំការជួយសង្គ្រោះ។

៧. អំពើជួញដូរមនុស្សនៅតែបន្តកើតឡើង។

៨. លុបបំបាត់ទាសភាពគ្រប់ទីកន្លែង ជារៀងរហូត។

៩. រៀងរាល់ ៣០វិនាទី មានមនុស្សម្នាក់ធ្លាក់ក្នុងទាសភាព។

១០. ៧០% នៃជនរងគ្រោះសរុបពីអំពើជួញដូរមនុស្សគឺជាស្ត្រី និង កុមារ ។

<u>ភាសាអង់គ្លេស៖</u>

1.Together to abolish slavery.
2.Human trafficking is also happening online.
3. Roughly 1 in 4 human trafficking victims are children.
4. End Human Trafficking!
5.There are millions of slaves in the world today.
6.99% of victims are never rescued.
7.Slavery still exists.
8.Abolish slavery everywhere forever.
9.Every 30 seconds someone becomes a slave.
1o.70% of detected human trafficking victims are women and girls.

មូលនិធិអេ២១
A21 FOUNDATION

រូបភាពគម្រូនៃការរចនាផ្ទាំងសារផ្សព្វផ្សាយ













រូបភាពគម្រូនៃការរចនាអាវយឺត






21
មូលនិធិអេ២១
A21 FOUNDATION

# ផែនទីបង្ហាញទីតាំងដើរផ្សព្វផ្សាយ

ក្នុងថ្ងៃប្រារព្ធព្រឹត្តិការណ៍បញ្ចប់អំពើជួញដូរមនុស្ស

ថ្ងៃអាទិត្យ ទី១១ ខែ តុលា ឆ្នាំ ២០២៣

**ទីតាំងជាក់ស្តែងលើផែនទី៖** https://www.google.com/maps/d/edit?mid=1Bg2NIAOzF-5Yo5FjB22-jAnTZ70Dq4&usp=sharing

**A = ទីតាំងចាប់ផ្តើមចេញដំណើរដើរ**

**B = ទីតាំងបញ្ចប់ដំណើរដើរ**

**■ = ទីតាំងរៀបចំកម្មវិធី**

**ចម្ងាយ = ២១០០ ម៉ែត្រ**




មូលនិធិអេ២១

A21 FOUNDATION

# <u>សមាសភាពអញ្ជើញចូលរួម</u>

ព្រឹត្តិការណ៍បញ្ឈប់អំពើជួញដូរមនុស្ស

ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២៣

១. លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍លេខាធិការដ្ឋាន គ.ជ.ប.ជ

២. លោកជំទាវ អភិបាលរងនៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍លេខាធិការដ្ឋាន គ.ខ.ប.ជ

៣. ក្រុមការងារនៃលេខាធិការដ្ឋាន គ.ខ.ប.ជ

៤. លោកស្រី ដួង ថាវរី ស្នងការរងខេត្តទទួលផែនប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៥. តំណាងមន្ទីរពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៦. តំណាងអង្គការជាតិនិងអន្តរជាតិដែលធ្វើការពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

៧. តំណាងសាកលវិទ្យាល័យ ឬ វិទ្យាស្ថាន

៨. តំណាងវិទ្យាស្ថានបណ្តុះបណ្តាលជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ

៩. សិស្សនិស្សិត

១០. អ្នកចូលរួមទូទៅ

<u>អ្នកចូលរួមសរុបចំនួន</u>៖ ៥០០ នាក់

មូលនិធិអេ២១
A21 FOUNDATION